FACT SHEET (Cambodian - Public Charge) 11/1/00

សេចក្តីណែនាំត្រួសៗពី " Public Charge "
នឹងការទទួលជំនួយសារធារណៈ (ជំនួយពីរដ្ឋ)

ការណែនាំត្រួសៗនេះ ជាការបញ្ជាក់ឲ្យដឹងពីការទទួលជំនួយពីរដ្ឋ នៅសហរដ្ឋអាមេរិកនឹងការទាក់ទង ឬ មិនទាក់ទងដល់ស្ថានភាពនៃជនអន្តោប្រវេសន៍នៅក្នុង "បន្ទុកសាធារណៈ" ទៅតាមច្បាប់អន្តោរប្រវេសន៍ ។

" Public Charge " គឺជាជនដែលការទទួលខុសត្រូវ ជាបន្ទុកដល់រដ្ឋាភិបាល ។

- **ជនអន្តោរប្រវេសន៍ ដែលដាក់ពាក្យសុំជាជនរស់នៅស្របច្បាប់ "LPRs"**
  (ដែលពុំទាន់មានត្រិនកាតនៅឡើយ)

  - ជនអន្តោរប្រវេសន៍មិនអាចចាត់ថាជា"បន្ទុកសាធារណៈ" ក្នុងការប្រើរ :

    - **HEALTH CARE BENEFITS:** ជំនួយខាងថែរទាំសុខភាពរួមទាំងមេឌីខេត កម្មវិធីធានាសុខភាពសំរាប់កុមារ (CHIP) ការថែរទាំស្ត្រីមានផ្ទៃពោះ ឬ ការព្យារបាលដោយឥតគិតថ្លៃ ឬ ដោយយកតម្លៃតិចនៅតាមមណ្ឌលព្យារបាលរោគ ឬ ត្រិះស្ថានផ្សេងៗទៀត លើកលែងតែកន្លែងដែលព្យារបាលឥយូរ ដូចជាត្រិះស្ថានថែរទាំជនជរាពិការ ឬមណ្ឌលដែលស្រដៀងគ្នា ។

    - **FOOD PROGRAMS :** កម្មវិធីផ្តល់ម្ហូបដូចជាប័ណ្ណទិញម្ហូប **WIC** (កម្មវិធីពិសែសក្នុងការផ្តល់ម្ហូបបន្ថែមដល់ស្ត្រី ទារក នឹងកូនក្មេង) ការផ្តល់ម្ហូបតាមសាលារៀន ឬ ជំនួយម្ហូបផ្សេងៗទៀត ។

- **OTHER PROGRAMS THAT DO NOT GIVE CASH** : កម្មវិធីជំនួយផ្សេងទៀតដែលមិនឲ្យជាប្រាក់ដូចជា កម្មវិធីផ្ទះសាធារណៈ ជំនួយថែទាំក្មេង ជំនួយឃាមពល (ប្រេងកំដៅ-ភ្លើង...) ជំនួយពេលមហន្តរាយ កម្មវិធី (Head Start) ដូចជាមតេយ្យសាលា ការបង្រៀនការងារផ្សេងៗ ជំនួយសត្តិអារមណ៍ នឹងឲ្យដំបូន្មាន ។

□ **ក្រសួងអន្តោប្រវេសន៍ (INS) នឹងពិនិត្យជនអន្តោប្រវេសន៍ដែលប្រើកម្មវិធីខាងក្រោមក្នុងការចេញគ្រិនកាតឲ្យ ។**

- **CASH WELFARE,** ប្រាក់ជំនួយ ; (SSI) ប្រាក់ជំនួយបន្ថែម ; (TANF) ប្រាក់ជំនួយបន្ទោះអាសនន៍ដល់គ្រួសារដែលខ្វះខាត នឹងជំនួយទូរទៅពីរដ្ឋ ។
- **INSTITUTIONALIZATION,** ការតម្រូវឲ្យនៅមន្ទីពេទ្យបាលក្នុងរយៈពេលយូរ ដូចជានៅកន្លែងថែទាំមនុស្សចាស់នឹងជនពិការ ឬ កន្លែងមណ្ឌលពេទ្យបាលរោគក្រិសៃប្រសាទដែលតម្រូវឲ្យរដ្ឋាភិបាលចេញប្រាក់កាស ។

សំគាល់ : ក្រសួងអន្តោប្រវេសន៍នឹងមិនចាត់ទុកថាក្រុមគ្រួសារជនអន្តោប្រវេសន៍ដែលទទួលប្រាក់ឧបត្ថម្ភរបស់ផ្សេងទៀតជាជំនួយថាជាបន្ទុកដល់រដ្ឋទេ លើកលែងតែជំនួយជាប្រាក់នោះ ជាថវិការតែមួយគត់សំរាប់គាំទ្រគ្រួសារនោះ ។

■ **ជនអន្តោប្រវេសន៍ស្របច្បាប់ នៅទីនេះជ្រើយ ហើយមានគ្រិនកាត : L P Rs**

L P Rs ជនអន្តោប្រវេសន៍ជំពូកនេះមិនអាចចាត់បង់សិទ្ធិដោយត្រូវគេដកហូតគ្រិនកាតទេ ក្នុងលក្ខណៈដែលគេឬក្រុមគ្រួសារគេប្រើជំនួយខាងក្រោម :

- ជំនួយថែទាំសុខភាព កម្មវិធីជំនួយម្ហូប ឬកម្មវិធីឯទៀតដែលគ្មានប្រើប្រាក់
- ប្រាក់ជំនួយ ដែលហ្ស្ស (មើលកំណត់ខាងក្រោម ក្នុងការអនុគ្រោះ)
- ការថែទាំយូរពេលវេលា (មើលកំណត់ខាងក្រោម ក្នុងការអនុគ្រោះ)

សំគាល់:

- ជនអន្តោប្រវេសន៍ស្របច្បាប់ដែលនៅទីនេះយូរមកហើយ អាចត្រូវក្រសួងអន្តោប្រវេសន៍សាកសួរ ថាគាត់នៅក្នុងបន្ទុករដ្ឋឬទេនៅពេលដែលអ្នកនោះចូលមកកាន់សហរដ្ឋវិញក្នុងលក្ខណៈដែលគេចាកចេញពីស្រុកនេះលើសពី ៦ខែរហើយ ការទទួលប្រាក់ជំនួយវ៉ែលហ្វែ ឧ ការថែទាំជ័យរពេលអាចត្រូវដោះស្រាយ។

- ក្នុងករណីខ្លះ: ជនស្របច្បាប់ ដែលយកប្រាក់វ៉ែលហ្វែរនឹងប្រើការថែទាំយូរពេលក្នុងកំឡុង ៥ឆ្នាំដំបូងដែលគាត់មកនៅស្រុកនេះ (ដោយសារពិការ ឬ មានជម្ងឺ) មុនពេលដែលគាត់មកកាន់ សហរដ្ឋ អាចត្រូវគេបញ្ជូនត្រឡប់ទៅវិញ ដោយសារគាត់ជាបន្ទុកដល់រដ្ឋ ។

- **ជនភៀសខ្លួន ឧ ឧ ដែលរដ្ឋអនុញ្ញាតឲ្យជ្រកកោននៅទីនេះ:** អាចប្រើជំនួយផ្សេងៗ តាំងពីប្រាក់វ៉ែលហ្វែ ការថែទាំជម្ងឺ ជំនួយបណ្ណ៌ម្ហូប ឧ ជំនួយផ្សេងៗ ទៀតដោយមិនមានការប៉ះពាល់ដល់ការទទួលគ្រិនកាត ។

- **ការធានាបងប្អូន** ជនជាតិអាមេរិកាំងនឹងអ្នករស់នៅស្របច្បាប់ អាចធានាបងប្អូនបាន ទោះបីគេទទួលជំនួយផ្សេងៗ ដូចជាប្រាក់វ៉ែលហ្វែ ជំនួយខាងថែទាំសុខភាព ជំនួយម្ហូបអាហារ ឧ ជំនួយផ្សេងៗទៀតដែលមិនឲ្យជាប្រាក់ក៏ដោយ ។ ក៏ប៉ុន្តែ អ្នកធានា(ឧ អ្នកជួយធានា)ត្រូវមានធ្វើរសំបុត្រធានារាប់រង (Affidavit of Support) បញ្ជាក់ថាគេមានប្រាក់ត្រប់ត្រាន់ ក្នុងការផ្គត់ផ្គង់ដល់បងប្អូននោះ ដោយមានចំនួន ១២៥ ភាគរយនៃកំពស់ ភាព ក្រីក្រ ។

- **ការចូលសញ្ជាតិអាមេរិកាំង** - LPRs អ្នករស់នៅស្របច្បាប់ (ដែលមានគ្រិនកាត) ដែលទទួលជំនួយពីរដ្ឋតាមច្បាប់ មានសិទ្ធិគ្រប់ត្រាន់ក្នុងការសុំចូលសញ្ជាតិអាមេរិកាំង។

ត្រូវការពត៌មានថែមទៀត ?

ជាពត៌មានថែមទៀតអំពី "បន្ទុកសាធារណៈ" **" Public Charge "**

សូមមើលក្រសួងអន្តោប្រវេសន៍ INS Web site : w w w. ins.usdoj.gov សម្រាប់កំណត់បញ្ជាក់ និង ចំឡើយចំពោះសំនួរផ្សេងៗ ។ ពត៌មានអាចផ្តល់ជូនជាភាសាផ្សេងៗ ក្នុងតារាង "កិច្ចការសាធារណៈ" (Public Affairs) ។

ដើម្បីជាពត៌មានថែមទៀត ក្នុងការចុះឈ្មោះក្នុងកម្មវិធីជំនួយនេះ

សូមអញ្ជើញទាក់ទងនឹងក្រសួងទទួលខុសត្រូវរបស់ (រដ្ឋាភិបាល) សហព័ន្ធ រដ្ឋ និង តាមដំបន់ ។ ខាងក្រោមនេះជាទីទាក់ទងសំខាន់ៗ :

សម្រាប់ CHIP : 1-877-543 7669. (ទូរសព្ទ៍មិនគិតលុយ)

សម្រាប់ហ្វូតស្តែម Food Stamps: 1-800-221 5689. (ទូរសព្ទ៍មិនគិតលុយ)

សម្រាប់មេឌីខេត Medicaid TANF : www.hhs.gov

សម្រាប់ WIC : www.fns.usda.gov

* នេះជាអត្ថបទដែលបានបកប្រែ អត្ថបទផ្លូវការមានជាភាសារអង្គេស ។